លេខសំគាល់៖ _______________
កាលបរិច្ឆេតប្រជុំ៖ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១៩

# សេចក្តីសំម្រេចលេខ ៣៧៦៧

សេចក្តីសម្រេច របស់គណៈកម្មាការកំពង់ផែនៃទីក្រុង*ស៊ីអាថល* បានបង្កើតសារាចរណ៍ស្តីពីគោលនយោបាយនៃកិច្ចសន្យាផលលាភរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ដើម្បីធ្វើការណែនាំអំពីការអនុវត្តកម្មវិធីសមភាពរបស់សហគមន៍ជ្រលងភ្នំ*ឌូវ៉ាមីស្ស* និងប្រតិបត្តិការរបស់កំពង់ផែផ្សេងៗទៀតដែលមានផលប៉ះពាល់ទៅលើសហគមន៍ជ្រលងភ្នំ ឌូវ៉ាមីស។

កំពង់ផែនៃទីក្រុងស៊ីអាថលបានប្តេជ្ញាបង្កើតឱកាសដែលអោយអាចប្រជាជនគ្រប់គ្នា ធ្វើអាជីវកម្ម ហើយនិងបានដឹកនាំការថែរក្សាបរិស្ថានរបស់យើងប្រកបដោយការទទួលខុសត្រូវ។ កំពង់ផែនៃទីក្រុង*ស៊ីអាថល* ក៏បានប្តេជ្ញាធ្វើជាដៃគូរបស់សហគមន៍ដែលនៅតំបន់ជុំវិញ ចូលរួមការលើកកម្ពស់សមភាពនិងការទទួលខុសត្រូវសង្គមប្រកបដោយតម្លាភាពហើយនិងគណនេយ្យភាព ។

កម្មវិធីមួយរយឆ្នាំរបស់កំពង់ផែបានលើកឡើងថា កំពង់ផែនឹងប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ក្នុងមានជាស្ថាប័នដែលជួយលើកកម្ពស់សហគ្រាសអាជីកម្មដែលមានស្រ្តីឬជនជាតិភាគតិចជាម្ចាស់អាជីវកម្ម ហៅកាត់ថា (WMBE) និងអាជីវកម្មខ្នាតតូច រួមទាំងជាស្ថាបន័ដែលលើកកំពស់ការអភិវឌ្ឍពលករ ដោយបង្កើននូវវគ្គបំពាក់បំប៉នពលករ បង្កើននូវចំនួនការងារនិងបង្កើនឱកាសក្នុងការធ្វើអាជីវកម្មដល់ប្រជាជននៅក្នុងតំបន់ នៅក្នុងវិស័យដូចជា ពាណិជ្ជកម្ម ទេសចរ និងដឹកជញ្ជូន។

កម្មវិធីមួយរយឆ្នាំរបស់កំពង់ផែ ក៏បានលើកឡើងថា កំពង់ផែនឹងធ្វើជាកំពង់ផែដែលយកចិត្តទុកដាក់បំផុតទៅលើការការពារបរិស្ថាននិងសន្សំថាមពលបំផុតនៅអាមេរិចខាងជើង ដោយផ្តោតទៅលើការកាត់បន្ថយនូវផ្សែងពុល ការបំភាយឧស្ម័នកាបូនិច ស្តារនិងកែលំអរ បង្កើតនិងបង្កើនជំរកសត្វព្រៃចំនួនសែសិបអេការ(40 acres) បន្ថែមទៀតនៅតំបន់ ផ្ទៃទឹក *គ្រីន/ឌូវ៉ាមីស្ស* និង នៅតាមឆក*អេលុត*។

កំពង់ផែ បានទទួលស្គាល់ថា ការរើសអើងជាតិសាសន៍នៅក្នុងស្ថាប័នបានបណ្តាលអោយ មានវិសមភាពក្នុងការចែកចាយផលលាភនៃការរីកចំរើនផ្នែកសេដ្ឋកិច្ចរបស់កំពង់ផែ ព្រមទាំងធ្វើអោយមានការខូចខាតទៅលើបរិស្ថាននៅតាមសហគមន៍ដែលនៅជុំវិញកំពង់ផែ ជាពិសេស សហគមន៍ដែលកំពុងប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចសង្គម។

នៅឆ្នាំ២០១៧ គណៈកម្មាការកំពង់ផែបានអនុម័តសេចក្តីសំរេចលេខ **៣៧៣៦** ដែលធ្វើវិសោធនកម្ម ដោយសេចក្តីសម្រេចលេខ៣៧៤៦។ សេចក្តីសម្រេចនេះ បានបង្កើតសារាចរណ៍ស្តីពីគោលការណ៍ក្នុងការជ្រើសរើសបុគ្គលិកជាអាទិភាព ដើម្បីផ្តល់អោយកម្មករសំណង់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមតម្រូវការ មកពីតំបន់ដែលមានវិបត្តិសេដ្ឋកិច្ចនានានៃ *យីងខោនធី ចចថោន* និង *សៅផាក* នូវការងារដែលទទួលបានប្រាក់កំរៃសមរម្យសំរាប់ផ្គត់ផ្គង់គ្រួសារ ដោយបង្កើនលទ្ធភាពក្នុងការចូលរួមក្នុងគម្រោងផ្សេងៗរបស់កំពង់ផែ។

នៅឆ្នាំ២០១៨ គណៈកម្មាការកំពង់ផែបានអនុម័តសេចក្តីសម្រេចលេខ **៣៧៤៧** ដែលបង្កើតនូវសារាចរណ៍អំពីគោលការណ៍បដិសណ្ឋារកិច្ចរបស់កំពង់ផែ ដើម្បីបង្កើននូវការចូលរួមពីសហគមន៍ជនអន្តោប្រវេសន៍និងជនភៀសខ្លួន ព្រមទាំងបង្កើនការគំទ្រដល់ជនទាំងនេះ។

នៅឆ្នាំ២០១៨ គណៈកម្មាការកំពង់ផែបានអនុម័តសេចក្តីសម្រេចលេខ **៣៧៣៧** ដែលបង្កើតនូវភាពចម្រុះនៅក្នុងសារាចណ៍អំពីគោលការណ៍កិច្ចសន្យា ដើម្បីផ្តល់ឱកាសជាអតិបរមារ សំរាប់បង្កើនការចូលរួមពីសហគ្រាសអាជីកម្មដែលមានស្ត្រីឬជនជាតិភាគតិចជាម្ចាស់អាជីវកម្ម (WMBE) នៅក្នុងគម្រោងកិច្ចសន្យារបស់កំពង់ផែនាៗ ដូចជា៖ ការងារសាធារណៈ ការផ្តល់សេវាពិគ្រោះយោបល់ ការផ្គត់ផ្គង់សម្ភារៈបរិក្ខារ ឧបករណ៍ និង សេវាកម្មផ្សេងៗទៀត។

នៅឆ្នាំ២០១៩ គណៈកម្មាការកំពង់ផែបានបង្កើត ការិយាល័យសមធម៌ ភាពចម្រុះនិងការរួបរួមគ្នា ដើម្បីឆ្លើយតបនឹងបញ្ហាការរើសអើងជាតិសាសន៍និងបង្កើននូវភាពស្មើគ្នា ភាពចំរុះ រួមទាំងការរួបរួមគ្នា ក្នុងគោលនយោបាយរបស់កំពង់ផែអំពីដំណើរការ និងកម្មវិធីផ្សេងៗ។

សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* បង្កើតដោយប្រជាជនមួយក្រុមនិងអង្គការនានា ដែលរស់នៅ ធ្វើការ កំសាន្ត សិក្សា និង ប្រតិបត្តសាសនា នៅក្នុងសង្កាត់នានាដែលនៅក្បែរកំពង់ផែដូចជា៖ *សៅផាក ចចថោន* និង តាមដងទន្លេ *ឌូវ៉ាមីស* ព្រមទាំងក្រុមប្រជាជនដែលធ្លាប់ទទួលរងគ្រោះ ឬកំពុងរងគ្រោះដោយភាពអយុត្តិធម៏ផ្នែកសេដ្ឋកិច្ច ការរើសអើងជាតិសាសន៍ និងអយុត្តិធម៏ក្នុងសង្គម។ ប្រជាជនទាំងនេះរួមមាន ប្រជាជននៅតំបន់ *ឌូវ៉ាមីស្ស* និង ប្រជាជនដែលតាំងទីលំនៅដំបូងនៅទីក្រុង *ស៊ីអាថល*។ ការកែសម្រួលនៃនិយមន័យនេះត្រូវឆ្លងកាត់ការអនុម័តពីដៃគូទាំងឡាយរបស់សហគមន៍។

នៅឆ្នាំ២០១៣ ការវិភាគអំពីការកើនឡើងនៃផលប៉ះពាល់សុខភាព ដែលបានបោះពុម្ពដោយក្រុមសកម្មភាពសុខភាព (Health Action) និង ក្រុមការងារបោសសំអាតនៃទន្លេ *ឌូវ៉ាមីស្ស* ឬ ក្រុមផ្តល់ប្រឹក្សាផ្នែកបច្ចេកទេស បានចាត់ទុកសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ជាកន្លែងដែលមានបញ្ហាអយុត្តិធម៌ក្នុងសង្គម ដោយហេតុថាតំបន់នេះមានបញ្ហាដូចជា ភាពមិនសមាមាត្រគ្នារវាងការប្រឈមមុខនឹងខ្យល់ពុល ការខ្វះនូវលំហរបៃតង និង អត្រាភាពក្រីក្រខ្ពស់ដែលបណ្តាលឲ្យអាយុកាលរំពឹងទុក នៅតំបន់ *សៅផាក* និង *ចចថោន* ១៣ឆ្នាំទាបជាងសហគមន៍អ្នកមាននានានៃទីក្រុង *ស៊ីអាថល។*

របាយការណ៍របស់ទីក្រុង *ស៊ីអាថល* នៅឆ្នាំ២០១៧ ស្តីពីការរៀបចំយុទ្ធសាស្រ្តប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ បានកំណត់ថា សហគមន៍នេះជាសហគមន៍មួយដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការប្រែប្រួលអាកាសធាតុ ដូចជា៖ ការកើនឡើងនៃកំដៅ និងរយៈកំពស់ទឹកសមុទ្រ ព្រមទាំងទឹកជំនន់។

គណៈកម្មាការកំពង់ផែ ព្យាយាមគំរូតាមសេចក្តីសម្រេចរបស់ទីក្រុង *ស៊ីអាថល* លេខ៣១៦៧ និង *យីងខោនទី ម៉ូសិន*(King County Motion) លេខ២០១៥-០១៦៧ ដែលទាក់ទងជាមួយនឹងការសំអាតផ្លូវទឹក សុខភាពសហគមន៍ដែលនៅជាប់នឹងផ្នែកខាងក្រោមនៃផ្លូវទឹក *ឌូវ៉ាមីស្ស* ស្ថាប័នសាធារណៈដែលបានដឹងពីវិសមភាពដែលសហគមន៍ធ្លាប់ទទួលនិងកំពុងប្រឈមមុខនាពេលបច្ចុប្បន្ន និងបានបើកដំណើរការផ្តួចផ្តើមគំនិតសំរាប់អនាគត ដោយប្រើប្រាស់វិធានការរបស់ពួកគេផ្ទាល់ ដូចជា ផែនការសកម្មភាព *ឌូវ៉ាមីស្ស* របស់ទីក្រុង *ស៊ីអាថល* ដែលឆ្លើយតបនឹងយុត្តិធម៌សង្គម និងការអភិវឌ្ឍន៍ប្រកបដោយសមភាពនៅក្នុងសហគមន៍។

គណៈកម្មាការកំពង់ផែធ្លាប់មានប្រវត្តិទំនាក់ទំនងជាមួយ សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* តាមរយៈការផ្តល់ថវិកាជាទ្រង់ទ្រាយធំសំរាប់ការសំអាតនិងកែលម្អ ក្នុងនាមជាផ្នែកមួយនៃក្រុមការងារផ្លូវទឹក *ឌូវ៉ាមីស្ស* ផ្នែកខាងក្រោម (LDWG) រួមជាមួយនិងទីក្រុង *ស៊ីអាថល យីងខោនធី* និង ក្រុមហ៊ុនប៊ូអ៊ីង។ ក្រុមការងារផ្លូវទឹក *ឌូវ៉ាមីស្ស* ផ្នែកខាងក្រោម (LDWG) បានវិនិយោគទឹកប្រាក់ប្រមាណ ហាសិបលានដុល្លាសហរដ្ឋអាមេរិក (USD 50 millions) ដើម្បីស៊ើបអង្កេតរកមូលហេតុនៃការបំពុលផ្លូវទឹកផ្នែកខាងក្រោមនៃទន្លេ *ឌូវ៉ាមីស្ស* និង ចាត់វិធានការក្នុងការសំអាតផ្លូវទឹកនេះ ហើយរកមធ្យោបាយការពារ ដោយគ្រប់គ្រងប្រភពដើមនៃការបំពុលនេះ។ កំពង់ផែ សៀអាធល ម្នាក់ឯងបានបានវិនិយោគជិត ដប់បីលានដុល្លាសហរដ្ឋអាមេរិក (USD 13 millions) ក្នុងការសម្អាតស្ថានីយតំបន់សកម្មភាពដំបូង១១៧ (117 Early Action Area)។

សម្ព័ន្ធកំពង់ផែសមុទ្រភាគពាយ័ព្យ និង កំពង់ផែនៃទីក្រុង *ស៊ីអាថល* បានធ្វើជាដៃគូគ្នាក្នុងការផ្តួចផ្តើមគំនិតមួយចំនួន ក្នុងការធ្វើឲ្យគុណភាពខ្យល់ប្រសើរឡើង និង កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (Greenhouse gases) ដូចជា៖ កម្មវិធីឡានដឹកទំនិញដែលមិនបំភាយផ្សែងពុល គម្រោងអប់រំអំពីគុណភាពខ្យល់ និងការអនុម័តនៃយុទ្ធសាស្រ្តខ្យល់បរិសុទ្ធរបស់កំពង់ផែភាគពាយ័ព្យដើម្បីកាត់បន្ថយផ្សែងពុល បណ្តាលមកពីការដឹកជញ្ជូននិងការប្រតិបត្តិការរបស់កំពង់ផែនៅលើអាងផ្ទៃទឹក *ចចជា* និង *ភូជីសោន* ពីការគ្រប់គ្រងឧបករណ៍សម្រាប់លើកដាក់ទំនិញ ខ្សែផ្លូវដែក យានកំពង់ផែ កប៉ាល់ និង ឡានដឹកទំនិញ។

នៅខែមករា ឆ្នាំ២០១៧ ភ្នាក់ងារការពារបរិស្ថានរបស់សហរដ្ឋអាមេរិករបស់កំពង់ផែ បានជ្រើសរើសគណៈកម្មាការកំពង់ផែ និងសមាគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ដើម្បីទទួលយកថវិកាសំរាប់ជំនួយការផ្នែកបច្ចេកទេសដើម្បីបង្កើតគម្រោងសាកល្បង ដែលគម្រោងនេះបានជួយសម្របសម្រួលកិច្ចសន្ទនា និងការចូលរួមពីសំណាក់សហគមន៍ដែលកំពុងប្រឈមមុខនឹងបញ្ហាយុត្តិធម៌សង្គម។

គម្រោងសាកល្បងនេះបានផ្តល់លទ្ធភាពឲ្យកំពង់ផែ កំណត់បាននូវកិច្ចសហការលើបីវិស័យ និង ការព្រមព្រៀងក្នុងការបែងចែកផលលាភជាមួយសហគមន៍ ដូចជា៖ ការកសាងសមត្ថភាព វិធានការគ្រប់គ្រងបរិស្ថាន

និងការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីបង្ការការផ្លាស់ប្តូរលំនៅដ្ឋានរបស់សហគមន៍។ វិសយ័ទាំងបីនេះ ក៏ដូចជាក្រុមការងារដែលបង្កើតដោយសហគមន៏ ដូចជាក្រុមការងារសកម្មសហគមន៍របស់កំពង់ផែ ហៅកាត់ថា(PCAT) គឺជាសសរទ្រូងសំខាន់សម្រាប់រក្សានូវភាពជាបន្តបន្ទាប់។ កំពង់ផែបានបង្កើនលុយដល់ទៅជាង បួនរយហាសិបពាន់ដុល្លារសហរដ្ឋអាមេរិក (USD 450,000) ទៅលើកម្មវិធីសហគមន៍ដូចជា ការកែលំអរមោត់ច្រាំង ការបង្កើនភាពងាយស្រួលក្នុងការចូលរួមក្នុងកម្មវិធីអប់រំសាធារណៈ និងកម្មវិធីតម្រង់ទិសសម្រាប់អាជីពការងារដែលទាក់ទងនឹងការថែរក្សាបរិស្ថាន។

ក្រុមសកម្មភាពសហគមន៍របស់កំពង់ផែ ហៅកាត់ថា(PCAT) គឺជាក្រុមអ្នកផ្តល់ប្រឹក្សាដែលសហគមន៍ប្រមូលផ្តុំ។ ក្រុមនេះត្រូវបានបង្កើតឡើងនៅឆ្នាំ2017 ជាផ្នែកមួយនៃគំរោងសាកល្បងកើតចេញពីសមាជិកសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស*។ គម្រោងនេះបានភ្ជាប់កំពង់ផែទៅក្នុងកិច្ចសហប្រតិបត្តិការ និង គម្រោងយុទ្ធសាស្រ្តដែលឆ្លើយតបទៅនឹងភាពមិនសមាមាត្រពីអតីតកាលក៏ដូចជាបច្ចុប្បន្ន អំពីការកើនឡើងនៃផលប៉ះពាល់ដែលមានឥទ្ធិពលអាក្រក់ទៅលើសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស*។ ក្រុមការងារសកម្មសហគមន៍របស់កំពង់ផែក៏បានផ្តល់ការបណ្តុះបណ្តាល និងបង្រៀនបុគ្គលិកកំពង់ផែ អំពីការចូលរួមអនុវត្ត និងការយល់ដឹងពីវប្បធម៌ដើម្បីជានាបាននូវប្រសិទ្ធភាពក្នុងការសម្រេចបាននូវ កម្មវិធីមួយរយឆ្នាំ (the Century Agenda) ។

នៅខែឧសភា ឆ្នាំ២០១៩ គណៈកម្មាការកំពង់ផែបានអនុញ្ញាតអោយបង្កើតកម្មវិធីសមភាពនៃសហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ព្រមទាំងដឹកនាំបុគ្គលិកអោយសហការជាមួយសហគមន៍ជាដៃគូដើម្បីបង្កើតការអនុវត្តផលលាភរបស់សហគមន៍ដែលផ្តល់គោលដៅរួម និយមន័យ យុទ្ធសាស្រ្ត និងគម្រោងការងារជាចំនុចៗដែលអាចអនុវត្តបានព្រមទាំងលក្ខខណ្ឌនៃការវាយតម្លៃ។

ដូច្នេះគណៈកម្មាការកំពង់ផែនៃទីក្រុងសៀធលបានដោះស្រាយដូចតទៅៈ

**ផ្នែកទី ១.** ការអនុវត្តផលលាភរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ត្រូវបានបង្កើតឡើងដូចបានចែងក្នុងកិច្ចសិន្យា A ( Exhibit A )

**ផ្នែកទី ២.** ការអនុវត្តផលលាភរបស់សហគមន៍ជ្រលងភ្នំ *ឌូវ៉ាមីស្ស* ត្រូវដាក់ផ្លាក និងធ្វើកាតាឡុកអោយបានសមស្របទៅតាមសារាចរណ៍គោលការណ៍ទាំងឡាយរបស់គណៈកម្មាការ ហើយត្រូវធ្វើឱ្យអោយបុគ្គលិក និងសាធារណៈជនងាយស្រួលប្រើប្រាស់ និងទុកជាឯកសារអភិបាលកិច្ចនៃកំពុងផែនៃទីក្រុង*ស៊ីអាថល*។

អនុម័តដោយគណៈកម្មាការកំពង់ផែនៃទីក្រុងសៀធលនៅកិច្ចប្រជុំដែលបានកំណត់សំគាល់យ៉ាងត្រឹមត្រូវ។

ឯកសារនេះធ្វើឡើងនៅថ្ងៃទី............ខែ..............ឆ្នាំ២០១៩ ហើយត្រូវបានផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវនៅក្នុងសម័យប្រជុំ ដោយមានការចុះហត្ថលេខាពីគណៈកម្មាការដែលបានបោះឆ្នោតគាំទ្រនិងបោះត្រារបស់គណៈកម្មការ។

____________________________

____________________________

____________________________

____________________________

____________________________

គណៈកម្មាការកំពង់ផែនៃទីក្រុង*ស៊ីអាធល*